**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០១៨.....សហវ.ក្រ

រាជធានីភ្នំពេញ, ថ្ងៃទី២៧ខែ សីហា ឆ្នាំ២០០៧

# សេចក្តីជូនដំណឹង

**<u>ជំរាបមក</u>**

**លោកនាយក/លោកស្រីនាយិកាក្រុមហ៊ុនកាស៊ីណូទាំងអស់**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកត់សំគាល់ឃើញថា ក្នុងរយៈពេលកន្លងមកនេះមានក្រុមហ៊ុន កាស៊ីណូមួយចំនួនដែលទទួលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលបើកធ្វើអាជីវកម្មកាស៊ីណូ បាននិងកំពុងលួចបើកធ្វើអាជីវកម្មកាស៊ីណូតាមប្រព័ន្ធអ៊ិនធឺណែតដោយគ្មានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់ម្ចាស់អាជីវកម្មកាស៊ីណូទាំងអស់ ត្រូវបញ្ឈប់អាជីវកម្មកាស៊ីណូតាមប្រព័ន្ធអ៊ិនធឺណែតក្នុងបរិវេណកាស៊ីណូរបស់ខ្លួន ដោយពុំមានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចាប់ពីពេលជូនដំណឹងនេះតទៅ ។

ក្នុងករណីដែលក្រុមហ៊ុនកាស៊ីណូណាមួយមិនអនុវត្តតាមការណែនាំនេះ ហើយនៅតែលួចបន្តធ្វើអាជីវកម្មប្រភេទនេះតទៅទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងដកហូតអាជ្ញាប័ណ្ណអាជីវកម្មកាស៊ីណូរបស់ក្រុមហ៊ុនទាំងស្រុង ។

ទទួលបានសេចក្តីជូនដំណឹងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមថាម្ចាស់អាជីវកម្មកាស៊ីណូទាំងអស់ នឹងអនុវត្តតាមការណែនាំនេះអោយទទួលបានប្រសិទ្ធភាពខ្ពស់ ។

សូមលោកនាយក/លោកស្រីនាយិកា ទទួលនូវការរាប់អានពីខ្ញុំ

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

<u>ចំលងជូន</u> :
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- គណៈកម្មការទប់ស្កាត់ល្បែងស៊ីសងខុសច្បាប់
- អាជ្ញាធរខេត្ត-ក្រុង
"ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ